# ការធ្វើពង្រាងច្បាប់

## ក) សេចក្តីផ្តើម

ការធ្វើពង្រាងច្បាប់ គឺភារកិច្ចដ៏លំបាកមួយ ។ ការធ្វើពង្រាងច្បាប់អាចប្រៀបបានទៅនឹងការងាររបស់វិស្វករដែលធ្វើម៉ាស៊ីនដ៏ធំមួយ ។ ការងារនេះត្រូវការការគូរប្លង់ និងការរៀបចំសេចក្តីលំអិតផ្នែកបច្ចេកទេសជាច្រើន រហូតដល់ម៉ាស៊ីននេះអាចដំណើរការបានស្រួល និងល្អប្រសើរ ។ ប្រសិនបើគ្រប់ផ្នែករបស់ម៉ាស៊ីននេះមិនត្រូវគ្នា ឬប្រសិនបើមុខងាររបស់ម៉ាស៊ីននេះមិនត្រូវបានគេកំណត់ច្បាស់លាស់ ឬប្រសិនបើប្លង់ស្ថាបនាម៉ាស៊ីននេះមិនគោរពតាមគោលការណ៍មូលដ្ឋាននៃធម្មជាតិ និងរូបវិទ្យាទេនោះ ម៉ាស៊ីននេះនឹងទទួលរងនូវភាពតានតឹងផ្នែកខាងក្នុង និងខាងក្រៅ ហើយនឹងខូចជាមិនខាន ។

ដូច្នេះ មានតែអ្នកជំនាញច្បាប់ដែលបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍ប៉ុណ្ណោះ ទើបមានសមត្ថភាពតាក់តែងច្បាប់ថ្មីមួយដែលដំណើរការល្អបាន ។ ដើម្បីបង្រួមកុំឱ្យស្ថាប័ននីតិកម្មកម្ពុជាពឹងផ្អែកលើអ្នកជំនាញបរទេសច្រើនពេកនៅក្នុងវិស័យនេះ និងដើម្បីផ្តល់អំណាចដល់គណៈវិនិច្ឆ័យកម្ពុជាក្នុងការធ្វើពង្រាងច្បាប់ទាំងឡាយនៃប្រទេសរបស់ពួកគេនោះ វគ្គបណ្តុះបណ្តាលស្តីពីការធ្វើពង្រាងច្បាប់មួយចំនួន ត្រូវបានរៀបចំឡើងហើយ **សៀវភៅមួយចំនួនស្តីពីការធ្វើពង្រាងច្បាប់នៅប្រទេសកម្ពុជា** ត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំកន្លងទៅនេះ[២០] ។

អត្ថបទខាងក្រោមនិយាយអំពីការសិក្សាលើសៀវភៅទាំងនេះ និង អំពីការចូលរួមនៅក្នុងវគ្គបណ្តុះ-បណ្តាលស្តីពីការធ្វើពង្រាងច្បាប់ឯកទេសទាំងនោះ ដើម្បីទទួលបាននូវចំណេះដឹងជំនាញអំពីវិធីធ្វើពង្រាងច្បាប់ ។

សៀវភៅនេះ ចង់ផ្តល់នូវទស្សនៈរួមមួយទៅលើឧបសគ្គធំៗនៅក្នុងការធ្វើពង្រាងច្បាប់ ដើម្បីផ្តល់ចក្ខុវិស័យមួយចំនួននៅក្នុងកំហុសដ៏សាមញ្ញបំផុតដែលគេតែងតែបង្កើតឡើងនាពេលបច្ចុប្បន្ន នៅពេលធ្វើពង្រាងច្បាប់នានា ។ ដូច្នេះ អត្ថបទនេះ មានបំណងឱ្យ**សមាជិកសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាយ៉ាងហោចណាស់បានបញ្ចេញមតិ ទៅលើពង្រាងច្បាប់ថ្មីៗ** ក្នុងលក្ខណៈសម្របសម្រួល ជ្រាលជ្រៅ និងរិះគន់មួយ និងដើម្បីរិះរកសំណើមួយចំនួនសំរាប់ការកែលំអ ។ ចំណុចនេះរាប់បញ្ចូលទាំងការយល់ដឹងជាមូលដ្ឋានលើបញ្ហា និងឧបសគ្គនានាពាក់ព័ន្ធនឹងផ្នែក ផ្សេងៗរបស់ច្បាប់ និងមុខងាររបស់ផ្នែកច្បាប់ទាំងនេះ ។

## ខ) ខ្លឹមសារជាមូលដ្ឋាននៃច្បាប់

ដូចបានរៀបរាប់នៅក្នុងជំពូកនិយាយអំពីនីតិរដ្ឋរួចមកហើយ មុខងារចំបងរបស់ច្បាប់ គឺដើម្បីដោះស្រាយបញ្ហាដែលកើតចេញពីសិទ្ធិមនុស្សនៃសមាជិកផ្សេងៗដែលមានទំនាស់នៅក្នុងសង្គមមួយ ។ ដើម្បីផ្តល់នូវដំណោះស្រាយទំនាស់មួយដែលអាចអនុវត្តបាន ច្បាប់ត្រូវតែផ្តល់នូវចម្លើយចំពោះសំនួរជាមូលដ្ឋានទាំងបួននេះ :

[២០] សូមមើល មូលនិធិ ខុនរ៉ាត់ អាដេណូអឺរ (Konrad Adenauer Foundation): "សៀវភៅស្តីពីការធ្វើពង្រាងច្បាប់ និងនីតិកម្ម" និង ប៉ាទ្រិស្សៀ បារ (Patricia Baars) "សេចក្តីណែនាំជាក់ស្តែងស្តីពីការតាក់តែងច្បាប់" (២០០១) (ភាសាអង់គ្លេស និងភាសាខ្មែរ) ។

- តើការកំណត់របស់ច្បាប់ មាន**ដែនកំណត់**ប៉ុណ្ណា?
    - តើនរណាដែលជាកម្មវត្ថុនៃច្បាប់ (បុគ្គលដែលត្រូវបានគ្រប់គ្រងដោយច្បាប់)?
    - តើវិស័យ និងកម្មវត្ថុអ្វីខ្លះដែលត្រូវធ្វើកំណត់ដោយច្បាប់?
    - តើពេលណាជាពេលកំណត់សំរាប់ការអនុម័តច្បាប់?
- តើ**សិទ្ធិ និងករណីយកិច្ច** អ្វីខ្លះកំណត់ច្បាប់?
- តើ**ស្ថាប័ននីតិប្រតិបត្តិ**ណា**អនុវត្ត**ច្បាប់?
- ក្នុងករណីមានការរំលោភច្បាប់ តើត្រូវមាន**ទណ្ឌកម្ម**ដូចម្តេចខ្លះ?

ដូច្នេះ គ្រប់ច្បាប់យ៉ាងហោចណាស់ត្រូវមានបួនជំពូក ឬផ្នែកជាមូលដ្ឋានដែលទាក់ទងនឹងសំនួរទាំងនេះ ។

# ច្បាប់

## I) គោលបំណង និងនិយមន័យ

តាមធម្មតាផ្នែកខាងដើមនៃអត្ថបទច្បាប់ភាគច្រើន មានផ្នែកមួយដែលរាប់បញ្ចូលការពណ៌នាអំពីគោលបំណងនៃច្បាប់នោះហើយបន្ទាប់មកមានការពណ៌នាអំពីដែនកំណត់របស់វា ។ ផ្នែកនេះគឺជា ផ្នែកដែលច្បាប់ផ្តល់នូវនិយមន័យនៃអ្នកទទួលព្រមទាំងនិយមន័យនៃវិស័យ និងលក្ខខណ្ឌគ្របដណ្តប់ដោយការដាក់បញ្ញត្តិដោយច្បាប់ ។

## II) សិទ្ធិ និងករណីយកិច្ច (ការអនុញ្ញាត/ការហាមឃាត់)

នៅផ្នែកកណ្តាលនៃអត្ថបទច្បាប់ គេឃើញនូវការកំណត់យ៉ាងពិស្តារអំពីករណីយកិច្ច និងសិទ្ធិរបស់អ្នកដែលទទួលរងផលប៉ះពាល់ ។ ផ្នែកនេះ និយាយពីការហាមឃាត់ទៅលើអ្វីដែលអ្នកទទួលមិនគួរធ្វើ ព្រមទាំងការអនុញ្ញាតចំពោះអ្វីដែលពួកគេត្រូវធ្វើ ។ បើនិយាយដល់សិទ្ធិមនុស្ស ផ្នែកនេះគឺជាផ្នែកមួយដែលមានសារៈសំខាន់បំផុត ។

## III) ទីភ្នាក់ងារនីតិប្រតិបត្តិ និងដំណើរការរដ្ឋបាល

ផ្នែកបន្ថែមទៀតចែងអំពីថា តើទីភ្នាក់ងាររដ្ឋាភិបាលណាមួយដែលត្រូវអនុវត្ត និងត្រួតពិនិត្យច្បាប់ ។ ផ្នែកនេះរាប់បញ្ចូលសិទ្ធិ និងករណីយកិច្ចរបស់ស្ថាប័នរដ្ឋាភិបាល ។ ផ្នែកនេះសំដៅដល់ស្ថាប័នរដ្ឋាភិបាលដែលមានស្រាប់ ឬចែងយ៉ាងច្បាស់អំពីទីភ្នាក់ងាររដ្ឋាភិបាលថ្មីមួយដែលទទួលបន្ទុកលើការអនុវត្តន៏ និងការត្រួតពិនិត្យច្បាប់ ។ ត្រង់ផ្នែកនេះគេក៏អាចរកឃើញនូវសេចក្តីអនុញ្ញាតផ្សេងៗ សំរាប់ការប្រើនូវអំណាចពិសេស ព្រមទាំងអង្គនីតិបញ្ញត្តិប្រតិភូកម្មសិទ្ធិអំណាចក្នុងការចេញបទបញ្ញត្តិដល់អង្គនីតិប្រតិបត្តិ ហើយប្រហែលជាថែមទាំងមានការកំណត់លំអិតអំពីថវិកា និងហិរញ្ញវត្ថុរបស់អង្គនីតិប្រតិបត្តិទៀតផង ។ ផ្នែកនេះបានដាក់បញ្ចូលផងដែរនូវបញ្ញត្តិពិសេសអំពីដំណើរការរដ្ឋបាល និងការត្រួតពិនិត្យដោយតុលាការលើរដ្ឋបាលនោះ ។

## IV) អវសានបញ្ញត្តិ

តាមធម្មតា នៅផ្នែកចុងក្រោយនៃអត្ថបទច្បាប់ គ្របដណ្តប់ប្រធានបទដូចខាងក្រោម :

- ការពិន័យ និងការដាក់ទណ្ឌកម្មចំពោះប្រភេទនៃអំពើរំលោភច្បាប់ជាក់លាក់ ។
- រយៈពេលចូលជាធរមាននៃច្បាប់ និងអន្តរបញ្ញត្តិ ។
- និរាករណ៍ ឬការកែសម្រួលច្បាប់ដទៃទៀតដែលមានទំនាស់ ។